ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៥.០២៨.១១៥៨ [illegible]

ថ្ងៃចន្ទ ៧កើត ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២៤

# សេចក្តីជូនដំណឹង
## ស្តីពី
## ការដេញថ្លៃប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) លើកទី១៨៩

ធនាគារជាតិនៃកម្ពុជា សូមជូនដំណឹងដល់គ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងអស់ឱ្យបានជ្រាបថា ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) លើកទី១៨៩ ដែលមានតណប្រតិទាន ៩១ថ្ងៃ ១៨២ថ្ងៃ និង៣៦៤ថ្ងៃ នឹងត្រូវដាក់ឱ្យដេញថ្លៃនៅថ្ងៃអង្គារ ទី១០ ខែកញ្ញា ឆ្នាំ២០២៤ និងតណប្រតិទាន ៧ថ្ងៃនឹងត្រូវដាក់ឱ្យដេញថ្លៃនៅថ្ងៃព្រហស្បតិ៍ ទី១២ ខែកញ្ញា ឆ្នាំ២០២៤។ ការទូទាត់សម្រាប់ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) លើកទី១៨៩ គ្រប់តណប្រតិទាននឹងត្រូវធ្វើឡើងនៅថ្ងៃព្រហស្បតិ៍ ទី១២ ខែកញ្ញា ឆ្នាំ២០២៤។ ព័ត៌មានពាក់ព័ន្ធនឹងការដេញថ្លៃនេះ មានដូចតទៅ៖

- ពេលវេលាដាក់ដេញថ្លៃ : ចាប់ពីម៉ោង ៨:០០ ព្រឹក ដល់ ១១:០០ ព្រឹក
- នីតិវិធីដេញថ្លៃ : ទឹកប្រាក់ដាក់ដេញថ្លៃជាលានរៀល (លេខមូល) និងអត្រាការប្រាក់ដាក់ដេញថ្លៃជាភាគរយ (ពីរខ្ទង់ក្រោយក្បៀស)
- វត្ថុធានា : - NCD ឬ មូលបត្ររដ្ឋ ជាវត្ថុធានាត្រូវមានតណប្រតិទានធំជាង ឬ ស្មើនឹងតណប្រតិទានរបស់ LPCO
  - សម្រាប់ LPCO តណប្រតិទាន ៧ថ្ងៃ គ្រឹះស្ថានអាចប្រើប្រាស់សមតុល្យគណនីចរន្ត ជាវត្ថុធានាបាន
- Haircut លើវត្ថុធានាជាដុល្លារអាមេរិក : ៣%
- ទំហំទឹកប្រាក់ដេញថ្លៃអប្បបរមា : ២០០.០០០.០០០ (ពីររយលាន) រៀល
- ទំហំទឹកប្រាក់ដេញថ្លៃអតិបរមា : មិនកំណត់

ទំហំទឹកប្រាក់ដាក់ឱ្យដេញថ្លៃ អត្រាការប្រាក់ Haircut លើវត្ថុធានា និងថ្ងៃតណប្រតិទាន មានដូចតទៅ៖

| ប្រភេទ LPCO | ថ្ងៃតណប្រតិទាន | ទឹកប្រាក់ដាក់ឱ្យដេញថ្លៃ | អត្រាការប្រាក់ដាក់ដេញថ្លៃអប្បបរមា |
|---|---|---|---|
| ៧ថ្ងៃ(D07) | ១៩ កញ្ញា ២០២៤ | ៨៥.០០០.០០០.០០០ រៀល | ៣,៧៥% |
| ៩១ថ្ងៃ (D91) | ១២ ធ្នូ ២០២៤ | ២០.០០០.០០០.០០០ រៀល | ៤,០០% |
| ១៨២ថ្ងៃ (D182) | ១៣ មីនា ២០២៥ | ១០.០០០.០០០.០០០ រៀល | ៤,២៥% |
| ៣៦៤ថ្ងៃ (D364) | ១១ កញ្ញា ២០២៥ | ៥.០០០.០០០.០០០ រៀល | ៤,៥០% |



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ការដេញថ្លៃនឹងធ្វើតាមរយៈថ្នាលធនាគារជាតិនៃកម្ពុជា (NBCP) តាមកាលវិភាគដែលបានកំណត់។ ក្នុងករណី NBCP មិនអាចអនុវត្តបាន គ្រឹះស្ថានត្រូវបញ្ជូនពាក្យសុំដេញថ្លៃតាមសារអេឡិចត្រូនិក marketoperations@nbc.gov.kh ឬដាក់ក្នុងស្រោមសំបុត្របិទជិត និងផ្ញើមកនាយកដ្ឋានទីផ្សាររូបិយវត្ថុ ឱ្យបានមុនម៉ោង ១១:០០ ព្រឹក នៅថ្ងៃដេញថ្លៃ។

លទ្ធផលនៃការដេញថ្លៃនឹងប្រកាសនៅម៉ោង ២:០០ រសៀល នាថ្ងៃដដែល។ គ្រឹះស្ថានដែលដេញថ្លៃឈ្នះត្រូវអនុវត្តតាមសេចក្តីណែនាំលើការអនុវត្តប្រតិបត្តិការ LPCO។

គណៈកម្មាធិការដេញថ្លៃរក្សាសិទ្ធិក្នុងការកែប្រែលក្ខខណ្ឌនៃការដេញថ្លៃប្រតិបត្តិការ LPCO។

**សូមទំនាក់ទំនង ៖**
លេខទូរស័ព្ទ : (៨៥៥-២៣) ៧២២ ២២១ EXT. ១០៥០
សារអេឡិចត្រូនិក : markets.info@nbc.gov.kh

**បណ្តាញសារព័ត៌មានផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា ៖**
www.nbc.gov.kh , www.facebook.com/nationalbankofcambodiaofficial ,
www.twitter.com/nbccambodia , www.instagram.com/nationalbankofcambodia ,
www.linkedin.com/company/national-bank-of-cambodia ,
www.youtube.com/channel/UC3GoCm_QGSSLjXZXvbcATfA